# ព្រឹត្តិបត្រក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ព័ត៌មានថ្មីៗអំពីទំនាក់ទំនងវិជ្ជាជីវៈ និងការដោះស្រាយវិវាទការងារនៅកម្ពុជា

ខែកក្កដា - កញ្ញា ឆ្នាំ២០១៣


## ដោះស្រាយវិវាទការងាររួម

### មាតិកា


- ការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ខែកក្កដា - កញ្ញា ឆ្នាំ ២០១៣ ១
- ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបង្រៀនថ្នាក់ដឹកនាំក្រុមប្រឹក្សាឃុំសង្កាត់ ពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ២
- ការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា ៣
- និស្សិតជប៉ុនរៀនពីប្រព័ន្ធដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ៤
- គ្លីនិកច្បាប់៖ និស្សិតរៀនអំពីដំណើរការដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងតុលាការ ៥
- ប្រវត្តិរូបអាជ្ញាកណ្ដាលៈ ពីក្មេងស្រុកស្រែទៅជាអាជ្ញាកណ្ដាលជោគជ័យមួយរូប ៥
- សកម្មភាពនៃពេលខាងមុខៈ រឿងកំប្លែងបែបអប់រំរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាលបន្តផ្សាយនៅ ស៊ីធីអិន ៦
- បុគ្គលិកថ្មី៖ ប្រធានផ្នែកបណ្ដុះបណ្ដាល និងទំនាក់ទំនង ៧
- ទទួលព័ត៌មានបច្ចុប្បន្នភាពស្ដីពីច្បាប់ការងារ ៨


## ការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ខែកក្កដា - កញ្ញា ឆ្នាំ ២០១៣

### ចំនួនសំណុំរឿងដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្នុងត្រីមាសទី ៣ ឆ្នាំ២០១៣



នៅក្នុងត្រីមាសទី៣ គិតពីខែកក្កដាដល់កញ្ញាឆ្នាំ២០១៣ គឺក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលបានសំណុំរឿងដែលចុះបញ្ជី ចំនួន៨៧សំណុំរឿង ដែលនេះគឺជាចំនួនសំណុំរឿងខ្ពស់បំផុត។ វាមានការកើនឡើងចំនួន ៣០% បើប្រៀបធៀបទៅនឹងចំនួនសំណុំរឿង ដែលចុះបញ្ជីចំនួន៦៧ ក្នុងត្រីមាសដូចគ្នាក្នុងឆ្នាំ ២០១២ និងកើនឡើងចំនួន ៧៧% ទៅនឹងចំនួនសំណុំរឿងដែលចុះបញ្ជីចំនួន៤៩ ក្នុងត្រីមាសដូចគ្នាក្នុងឆ្នាំ ២០១១។

ការកើនឡើងនៃចំនួនសំណុំនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល បង្ហាញពីការបន្តទុកចិត្ត និងជឿជាក់ក្នុងការដោះស្រាយវិវាទការងារ។ លើសពីនេះទៅទៀត ការកើនឡើងនេះ ក៏បង្ហាញពីការចូលចិត្តប្រើប្រាស់យន្តការដោះស្រាយវិវាទ ជាងការធ្វើកូដកម្ម ឬក៏ឡុកអៅដោយភាគីទាំងពីរ។

ក្នុងសំណុំរឿងចំនួន៨៧សំណុំរឿងក្នុងត្រីមាសនេះប្រភេទទាមទារពធំៗគឺ ១/ ប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗ ២/ សុខភាព និងសុវត្ថិភាពការងារ ៣/និងការទាមទារឲ្យចូលធ្វើការវិញរបស់ថ្នាក់ដឹកនាំសហជីព និងសមាជិក។ ក្នុងចំនោមសំណុំរឿងទាំងអស់ ៤៥% ត្រូវបានសម្រេចសេចក្ដីតាមរយៈសេចក្ដីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ២៥% តាមរយៈការផ្សះផ្សា ២៣% គឺត្រូវរង់ចាំដោះស្រាយនៅត្រីមាសបន្ទាប់ និង៧%ទៀត គឺបានបិទសំណុំរឿងដោយសារតែភាគី បន្តធ្វើកូដកម្ម ឬមិនចូលរួមសវនាការ។

## សេចក្ដីបញ្ជាឲ្យត្រលប់ចូលធ្វើការវិញ ដែលចេញដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាល ពីខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០១៣

តាមធម្មតា អាជ្ញាកណ្ដាលចេញសេចក្ដីបញ្ជាឲ្យត្រលប់ចូលធ្វើការវិញចំពោះសំណុំរឿងដែលមានកូដកម្ម។ ការចេញសេចក្ដីបញ្ជាឲ្យត្រលប់ចូលធ្វើការវិញនេះគឺដើម្បីធានាថាភាគីទាំងពីរផ្អាកកូដកម្ម និងត្រឡប់ចូលធ្វើការវិញនៅពេល ដែលវិវាទរបស់ពួកគេកំពុងត្រូវបានធ្វើការដោះស្រាយដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាលដោយសន្តិវិធី។ គោលបំណង នៃការចេញសេចក្ដីបញ្ជានេះ គឺដើម្បីរក្សាស្ថិរភាពឧស្សាហកម្ម ប្រាក់ឈ្នួល និងចំណូល។ ប្រសិនបើភាគីទាំងពីរមិនគោរពតាមសេចក្ដីបញ្ជាឲ្យត្រលប់ចូលធ្វើការ




*តទៅទំព័រ ២*

## ការដោះស្រាយវិវាទការងារ...

*តមកពីទំព័រ ១*

វិញទេ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងចេញសេចក្តីបង្គាប់បិទសំណុំរឿង។

ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៣ សំណុំរឿងដែលមានកូដកម្មចុះបញ្ជីនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន ១៨ មានកូដកម្ម។ តួលេខនេះគឺច្រើនជាង ៤ សំណុំរឿងធៀបទៅនឹងចំនួនសំណុំរឿងចុះបញ្ជីក្នុងរយៈពេលដូចគ្នានៅក្នុងឆ្នាំ២០១២។

ក្នុងចំណោមសំណុំរឿងទាំង ១៨ នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាឲ្យត្រលប់ចូលធ្វើការវិញចំនួន១០។ សំណុំរឿងចំនួន ៨ ផ្សេងទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានចេញសេចក្តីបញ្ជាឲ្យត្រលប់ចូលធ្វើការវិញទេ៖ ១) ១៥៤/១៣-បូវខឺ ហ្គាមិន ហ្វេកថូរី (ខេមបូឌា) ខូអិលធីឌី, ២) ១៦១/១៣-ស៊ីនឆាងស៊ីន, ៣) ១៦៦/១៣-ឡុងប្រាយ អេឡិកត្រូនិក អ៊ែនថីប្រាយ ខូអិលធីឌី, ៤) ១៧៣/១៣-ហ្វីស ហ្គារ៉ុន, ៥) ១៧៦/១៣-អ៊ីន (ខេមបូឌា) ខូអិលធីឌី, ៦) ១៩១/១៣-អ៊ែវើគ្លរី ខេមបូឌា ហ្គាមិន មែនូហ្វេកធើរីង ខូអិលធីឌី, ៧) ២០២/១៣-យូនីកស្តាថិចណូឡូជី (ខេមបូឌៀ) ខូអិលធីឌី, ៨) ២០៦/១៣-អានស៊ីង (ខេមបូ) ហ្គាមិន ហ្វេកថូរី លីមីតធីត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានចេញសេចក្តី បង្គាប់ឲ្យត្រលប់ចូលធ្វើការវិញទេដោយសារ៖ សហជីពដកសំណុំរឿង សំណុំរឿងនោះត្រូវបានដោះស្រាយតាមរយៈសេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬសំណុំរឿងកំពុងស្ថិតក្នុងនីតិវិធី។

ភាគីទាំងពីរអនុវត្តតាមសេចក្តីបញ្ជាឲ្យត្រលប់ចូលធ្វើការវិញចំនួន ៥ ក្នុងចំណោមសេចក្តីបញ្ជាចំនួន ១០។

## ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្រៀនថ្នាក់ដឹកនាំក្រុមប្រឹក្សាឃុំសង្កាត់ ពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ





កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ថ្នាក់ដឹកនាំក្រុមប្រឹក្សា ឃុំ សង្កាត់ មកពីខេត្តក្រុងនានាក្នុងប្រទេសកម្ពុជា បានជួបជុំគ្នានៅឯមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអភិបាលកិច្ចល្អក្នុងការិយាល័យសម្របសម្រួលគម្រោងនៃក្រសួងមហាផ្ទៃដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ដំណើរការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល និងវិធីសាស្រ្តនៃការចរចា" ដែលវគ្គបណ្តុះបណ្តាលនេះធ្វើដោយមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដោយមានកិច្ចសហការជាមួយការិយាល័យសម្របសម្រួលគម្រោង មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរៀបចំវគ្គសិក្សារយៈពេលមួយថ្ងៃ ដល់ថ្នាក់ដឹកនាំក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ១៥ មកពី ខេត្តក្រុងចំនួន ៥ ក្នុងប្រទេសកម្ពុជា។ គោលបំណងនៃវគ្គសិក្សានេះ គឺដើម្បីពង្រឹងសមត្ថភាពបន្ថែមដល់ថ្នាក់ដឹកនាំក្រុមប្រឹក្សា ឃុំ សង្កាត់ ទៅនឹងការដោះស្រាយវិវាទ ថ្នាក់ឃុំដោយប្រើយុទ្ធសាស្រ្ត នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីដោះស្រាយវិវាទ។

លោក ប៊ុត ជិ ប្រធានគម្រោង នៃការិយាល័យសម្រេនសម្រួលគម្រោងអភិបាលកិច្ចល្អមូលដ្ឋានដែលទទួលជំនួយពីធនាគារពិភពលោក បានមានប្រសាសន៍ថាតាមរយៈវគ្គសិក្សានេះ នឹងអាចទទួលចំណេះដឹងច្រើនពីដំណើរការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ពីព្រោះប្រព័ន្ធនេះគឺលឿន និងមិនស្មុគស្មាញ។

"នៅពេលមិនអាចដោះស្រាយបាន ប្រជាពលរដ្ឋមិនដឹងថាតើពួកគេគួរទៅសុំការជួយដោះស្រាយវិវាទរបស់ពួកគេនៅកន្លែងណាទេ" លោកបានមានប្រសាសន៍ដោយបន្ថែមទៀតថា "បើសិនជាពួកគេបញ្ជូនសំណុំរឿងទាំងអស់ រួមទាំងសំណុំវិវាទតូចតាចនោះ សំណុំរឿងនៅតុលាការនឹងមានភាពកកស្ទះ ដូច្នេះពួកគេគួរតែសុំការជួយដោះស្រាយវិវាទជាបឋមពីថ្នាក់ដឹកនាំឃុំរបស់ពួកគេ"។

ប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលធ្វើឡើងដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺបានទទួលវិវាទការងាររួមចំនួន ១៦០០ សំណុំរឿងក្នុងរយៈពេល ១០ឆ្នាំនេះ។

លោក សុខ ឡោ នាយកប្រតិបត្តិនៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានមានប្រសាសន៍ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមយ៉ាងពេញទំហឹងក្នុងការដោះស្រាយវិវាទដែលកើតឡើងក្នុងសហគ្រាស ពីព្រោះវាអាចកាត់បន្ថយភាពអស្ថិរភាពសង្គម កូដកម្ម ឬឡុកអៅ និងរក្សាប្រាក់បៀវត្ស ឬប្រាក់ចំណេញសម្រាប់ភាគីទាំងពីរ។

ក្នុងវគ្គបណ្តុះបណ្តាល ដែលធ្វើឡើងដោយអាជ្ញាកណ្តាល លីវ សុណ្ណា នេះ បានបែងចែកជាពីរវគ្គផ្សេងៗគ្នា។ វគ្គទី១ គឺស្តីពីដំណើរការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល និងវគ្គទី២ គឺយុទ្ធសាស្រ្តនៃការចរចា។ ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមក៏ត្រូវបានចែកជាក្រុមដើម្បីអនុវត្តករណីសិក្សាជាក់ស្តែង និងចែករំលែកបទពិសោធន៍ក្នុងការដោះស្រាយវិវាទ។

# ការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា



នៅឆ្នាំ២០១៣ ព្រឹត្តបត្រក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបន្តភាគនៃការអប់រំអំពីច្បាប់ដែលរៀបចំឡើងដើម្បីពន្យល់ ផ្នែកសំខាន់ៗរបស់ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧។ ក្នុងលេខនេះយើងនឹងពិភាក្សាអំពីប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងនៅកម្ពុជា។ យើងនឹងស្វែងយល់អំពីប្រាក់ឈ្នួលអប្បបរមា ថាតើត្រូវកំណត់ប្រាក់ឈ្នួលអប្បបរមាយ៉ាងដូចម្តេចក្រោមច្បាប់ស្តីពីការងារព្រមទាំងប្រវត្តិប្រាក់ឈ្នួលអប្បបរិមា និងការកំណត់ប្រាក់ឈ្នួលអប្បបរមានាពេលអនាគត។

## តើប្រាក់ឈ្នួលអប្បបរមាជាអ្វី?

ប្រាក់ឈ្នួលអប្បបរមាគឺជាឈ្នួលការងារ ឬឈ្នួលសេវាកំរិតដោយច្បាប់ជាតិ ដែលនិយោជកត្រូវបើកឲ្យកម្មករនិយោជិត។ ប្រាក់ឈ្នួលអប្បបរមាខុសពី “ប្រាក់ឈ្នួលសម្រាប់ការរស់នៅ” ដែលមានន័យថាជាប្រាក់ចំណូលអប្បបរមា ដែលកម្មករនិយោជិតម្នាក់ និងអ្នកនៅក្រោមបន្ទុករបស់គាត់ត្រូវការជាចាំបាច់សម្រាប់អាហារ ជម្រក និងសំលៀកបំពាក់។ នៅកម្ពុជា ប្រាក់ឈ្នួលអប្បបរមាត្រូវបានគេចាត់ថាជា “ប្រាក់ឈ្នួលអប្បបរមា ដែលត្រូវធានាដោយច្បាប់”។ មាត្រា ១០៤ នៃច្បាប់ស្តីពីការងារចែងថា ប្រាក់ឈ្នួលអប្បបរមាត្រូវបានរៀបចំឡើងដើម្បី “រ៉ាប់រងកម្មករនិយោជិតគ្រប់រូបឲ្យមានកំពស់ជីវភាពសមរម្យទៅតាមសេចក្តីថ្លៃថ្នូររបស់មនុស្ស”។

ប្រាក់ឈ្នួលអប្បបរមាអាចត្រូវបានកំណត់តាមកំរិតប្រាក់ឈ្នួល ឬប្រាក់សេវាប្រចាំម៉ោង ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែទាបបំផុត ហើយនៅកម្ពុជា ប្រាក់ឈ្នួលអប្បបរមាត្រូវបានគណនាតាមកំរិតកំណត់នៃប្រាក់ឈ្នួលប្រចាំខែ និងត្រូវបានរៀបចំឡើងសម្រាប់កម្មករនិយោជិតទាំងអស់នៅក្រោមច្បាប់ស្តីពីការងារ (មាត្រា ១០៧)។ អនុសញ្ញាជាលាយល័ក្ខណ៍អក្សរ ឬដោយមាត់ទទេណាដែលតម្រូវឲ្យឈ្នួលទៅ កម្មករនិយោជិតដោយអត្រាទាបជាងប្រាក់ឈ្នួលអប្បបរមា ដែលត្រូវធានាត្រូវទុកជាមោឃៈ ហើយគ្មានផលអ្វីឡើយ (មាត្រា ១០៥)។ ច្បាប់ស្តីពីការងារក៏គ្របដណ្តប់លើកម្មករនិយោជិត ធ្វើការទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផលហើយប្រាក់ឈ្នួលជាមធ្យមរបស់គាត់មិនអាចទាបជាងប្រាក់ឈ្នួលដែលត្រូវធានាទេ (មាត្រា ១០៨។)

## តើប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់យ៉ាងដូចម្តេច?

ប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់តាមរយៈការអនុម័តច្បាប់ស្តីពីការងារកម្ពុជាឆ្នាំ១៩៩៧ ហើយមាត្រា ១០៧ ផ្តល់យុត្តាធិការដល់ក្រសួងបណ្តុះបណ្តាល និងវិជ្ជាជីវៈក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាក្រោយការទទួលបានអនុសាសន៍ ពីគណៈកម្មការប្រឹក្សាការងារ ដែលជាគណៈកម្មការត្រីភាគីរួមមានតំណាងក្រសួងបណ្តុះបណ្តាល និងវិជ្ជាជីវៈ សមាគមនិយោជក និងសហជីព។

យោងតាមច្បាប់ស្តីពីការងារ មានការពិចារណាលើធាតុផ្សំមួយចំនួនក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា។ ធាតុផ្សំទាំងនេះរួមមាន ការវាយតម្លៃលើសេចក្តីត្រូវការរបស់កម្មករនិយោជិត (ដូចជាតម្លៃជីវភាពរស់នៅកំរិតប្រាក់បៀវត្ស និងកំរិតជីវភាពប្រៀបធៀប) ព្រមទាំងការពិចារណា



តទៅទំព័រ ៤

## ការកំណត់ប្រាក់ឈ្នួល...

*តមកពីទំព័រ ៣*

អំពីកត្តាទាំងឡាយ នៃវិស័យសេដ្ឋកិច្ច (ដូចជាការអភិវឌ្ឍសេដ្ឋកិច្ច ផលិតភាព និងកំរិតមុខរបរ)។

ប៉ុន្តែទោះបីជាមានចែងថា អ្នកណាមានអំណាចក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាក្តី ច្បាប់ស្តីពីការងារមិនបាន ផ្តល់យន្តការច្បាស់លាស់សម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមាដោយសារមិនមានការកំណត់អំពីរយៈពេលទៀងទាត់សម្រាប់ការត្រួតពិនិត្យឡើងវិញលើប្រាក់ឈ្នួលអប្បបរមា ឬការវាយតម្លៃឲ្យបានច្បាស់លាស់ចំពោះតម្លៃនៃជីវភាពរស់នៅ និងសូចនាករសេដ្ឋកិច្ច។

ដោយសារកត្តានេះហើយ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតគណៈកម្មការចម្រុះត្រីភាគីដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីកំរិតប្រាក់ឈ្នួលអប្បបរមាសមរម្យនៅ ខែសីហា ឆ្នាំ២០១៣។ គណៈកម្មការចម្រុះនេះមាន សមាសភាពដូចជា តំណាងរាជរដ្ឋាភិបាល សមាគមនិយោជក និងសហជីព។

ទន្ទឹមនឹងនីតិវិធីចែងក្នុងច្បាប់ស្តីពីការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់ប្រាក់ឈ្នួល អប្បបរមាចំនួន ៤០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ នៅឆ្នាំ១៩៩៧ ប៉ុន្តែការត្រួតពិនិត្យឡើងវិញលើប្រាក់ឈ្នួលអប្បបរមាមិនត្រូវបានធ្វើឡើងឲ្យបានទៀតទាត់ទេតាំងពីពេលនោះមក។ នៅឆ្នាំ២០០០ ប្រាក់ឈ្នួលអប្បបរមាត្រូវបានតម្លើងដល់ ៤៥ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ ៦ឆ្នាំក្រោយមក ប្រាក់ឈ្នួលនេះត្រូវបានតម្លើងដល់ ៥០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែនៅឆ្នាំ២០០៦។ ប្រាក់ឈ្នួលដដែលត្រូវបានតម្លើងសាជាថ្មីទៀតនៅឆ្នាំ ២០០៨ ដល់ ៥៦ ដុល្លារសហរដ្ឋអាមេរិករួមទាំងប្រាក់ឧបត្ថម្ភ និងដល់ ៦១ ដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០១០។ នៅខែឧសភាឆ្នាំនេះ គណៈកម្មការប្រឹក្សាការងារតម្លើងប្រាក់ឈ្នួលអប្បបរមា ១៤ ដុល្លារសហរដ្ឋអាមេរិកបន្ថែមទៀតដែលធ្វើឲ្យឡើងដល់ ៧៥ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ ការតម្រូវឲ្យដាក់បញ្ចូលប្រាក់ទ្រទ្រង់សុខភាព ៥ ដុល្លារសហរដ្ឋអាមេរិកក្នុងប្រាក់ឈ្នួលអប្បបរមាធ្វើឲ្យកម្មករនិយោជិតទទួលបានប្រាក់ឈ្នួល ៨០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។

ក្នុងសេចក្តីជូនដំណឹងលេខ ២០៩ ចេញនៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការរៀបចំកិច្ចពិភាក្សាស្តីពីការតម្លើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិត ទាំងអស់ក្នុងឆ្នាំ២០១៤ តាមរយៈយន្តការត្រីភាគីដោយមានសមាសភាព រាជរដ្ឋាភិបាលតំណាងនិយោជក និងសហជីព។

## និស្សិតជប៉ុនរៀនពីប្រព័ន្ធដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល





កាលពីថ្ងៃទី ១៩ខែសីហា ឆ្នាំ ២០១៣ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើជាម្ចាស់ផ្ទះទទួលនិស្សិតជប៉ុនចំនួន១៩ មកពីសកលវិទ្យាល័យ Aoyama Gakuin ដែលពួកគេទាំងនោះចាប់អារម្មណ៍ពីការដោះស្រាយវិវាទការងារនៅកម្ពុជា។

លោកអាជ្ញាកណ្តាល លី តៃសេង ដែលជាអ្នកបណ្តុះបណ្តាលនាពេលនោះ បានផ្តល់វគ្គបណ្តុះបណ្តាលពី “ប្រវត្តិរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល” និង “ការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល និងនៅតុលាការ” ដល់និស្សិតទាំងអស់នោះ។

លោកសាស្ត្រាចារ្យ Hisaaki Fujikawa ដែលដឹកនាំក្រុមទាំងនោះបានមានប្រសាសន៍ថាបទបង្ហាញនេះបានផ្តល់បទពិសោធន៍ជាបឋមដ៏មានគុណតម្លៃ ពីរបៀបដោះស្រាយវិវាទការងារអន្តរជាតិ ដែលនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ការសិក្សារបស់និស្សិតគាត់។

“ដោយសារតែនិស្សិតទាំងនេះកំពុងតែសិក្សាវិវាទការងារអន្តរជាតិ ខ្ញុំជឿថាការទស្សនកិច្ចស្ថាប័នទំនាក់ទំនងវិជ្ជាជីវៈដ៏ចំបងមួយក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងផ្តល់ការយល់ដឹងយ៉ាងជ្រាលជ្រៅបន្ថែមនៃប្រព័ន្ធដោះស្រាយវិវាទការងារ” គាត់បានមានប្រសាសន៍ដោយបន្ថែមទៀតថា

នេះគឺជាឆ្នាំទី៣ ដែលក្រុមនិស្សិតជប៉ុនបានមកទស្សនកិច្ចក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីសិក្សាដោយផ្ទាល់អំពីប្រព័ន្ធដោះស្រាយវិវាទការងារនៅកម្ពុជា។ ក្រុមទីមួយមកនៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១១ និងទីពីនៅ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១២។

# គ្លីនិកច្បាប់៖ និស្សិតរៀនអំពីដំណើរការដោះស្រាយវិវាទនៅ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងតុលាការ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅតែបន្តធ្វើការងារជាមួយសកលវិទ្យាល័យនានា ដើម្បីផ្ដល់វគ្គបណ្ដុះបណ្ដាលទៅលើការដំណើរការដោះស្រាយវិវាទការងារនៅកម្ពុជា តាមរយៈគ្លីនិកច្បាប់ដល់និស្សិត។ កាលពីថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៣ និស្សិតចំនួន២១នាក់ មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានចូលរួមវគ្គបណ្ដុះបណ្ដាលរយៈពេល២ម៉ោង ដែលធ្វើឡើងនៅការិយាល័យ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។



លោកអាជ្ញាកណ្ដាល ម៉ែន និម្មិត ដែលជាអ្នកបណ្ដុះបណ្ដាលក្នុងពេលនោះ បានធ្វើបទបង្ហាញយ៉ាងលម្អិតពីដំណើរការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងតួនាទីរបស់តុលាការ។ គាត់បាននិយាយថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺជាស្ថាប័នឯករាជ្យដែលដោះស្រាយវិវាទការងារផ្អែកទៅលើច្បាប់ស្ដីពីការងារ និងបទដ្ឋានអន្តរជាតិ។

"ប្រព័ន្ធដោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺអាចទុកចិត្តបានរហ័ស និងយុត្តិធម៌ ដែលអាចឲ្យកម្មករនិយោជិត និងនិយោជកទទួលផលប្រយោជន៍ទាំងសងខាងពីប្រព័ន្ធនេះ" លោកបានមានប្រសាសន៍ដោយបន្ថែមថា "នេះថែមទាំងអាចជួយបង្កើនទំនាក់ទំនងនៅកន្លែងការងារ លក្ខខណ្ឌការងារ និងរក្សាប្រាក់កម្រៃ និងប្រាក់ចំណូលផងដែរ"។

តាមរយៈវគ្គបណ្ដុះបណ្ដាលនេះ លោកអាជ្ញាកណ្ដាល ម៉ែន និម្មិត ក៏បានបង្ហាញពីភាពខុសគ្នារវាងក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងតុលាការទាក់ទងទៅនឹងការដោះស្រាយវិវាទផងដែរ។

"នៅក្នុងសេចក្ដីបង្គាប់ជាប់កាតព្វកិច្ច ភាគីទាំងអស់ឯកភាពគោរពទៅតាមសេចក្ដីបង្គាប់របស់អាជ្ញាកណ្ដាល។ ទោះបីជាយ៉ាងណាក៏ដោយ បើភាគីណាមិនគោរពតាមនោះភាគីម្ខាងទៀត អាចនាំយកសេចក្ដីសម្រេចនេះទៅតុលាការ ដើម្បីធ្វើការបង្ខំឲ្យអនុវត្តន៍"។

នៅចុងបញ្ចប់នៃវគ្គបណ្ដុះបណ្ដាល នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏ បានផ្ដល់ឱកាសដល់ក្រុមនិស្សិតនីមួយៗ ចូលរួមអង្កេតមើលជាក់ស្ដែងពីការដោះស្រាយវិវាទនៅក្នុងសវនាការរបស់ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ។



# ប្រវត្តិរូបអាជ្ញាកណ្ដាល: ពីក្មេងស្រុកស្រែទៅជាអាជ្ញាកណ្ដាលដ៏ជោគជ័យមួយរូប

ទោះបីជាបានចាប់កំណើតក្នុងគ្រួសារអ្នកស្រុកស្រែក្រីក្រមានលុយកាក់តិចតួចក្ដី បុរសវ័យ ៣៥ឆ្នាំរូបនេះបានខិតខំធ្វើការដ៏លំបាកដើម្បីតស៊ូជំនះនឹងភាពក្រីក្រដើម្បីក្លាយខ្លួនជាមនុស្សជោគជ័យ និងជាមនុស្សសំខាន់មួយរូបក្នុងការរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា។ ខ្លឹមសារខាងក្រោម នេះគឺជាបទសម្ភាសន៍ដាច់ដោយឡែកមួយជាមួយលោកលី តៃសេង ដែលជាអាជ្ញាកណ្ដាលរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបច្ចុប្បន្ន និងជានាយកគ្រប់គ្រងក្រុមហ៊ុនផ្ដល់ប្រឹក្សាច្បាប់ និងសារការីអេកប៊ីអេស (HBS Law Firm & Consultants-HBS and HBS Notary Public)។

**សំណួរ ១៖ សូមលោកជម្រាបអំពីប្រវត្តិសិក្សារបស់លោក?**

**ចម្លើយ៖** ខ្ញុំរៀនចប់ថ្នាក់ទី ១២ នៅខេត្តកណ្ដាល ដែលជាទីកំណើតរបស់ខ្ញុំ។ បន្ទាប់មកខ្ញុំបានបន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងទីក្រុងភ្នំពេញពីឆ្នាំ ១៩៩៦ ដល់ ២០០០។ បន្ទាប់ពីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ខ្ញុំទទួលបានអាហារូបករណ៍ទៅសិក្សានៅសាកលវិទ្យាល័យ ណាហ្គូយ៉ា ប្រទេសជប៉ុន។

**សំណួរ ២៖ តើលោកមានជួបប្រទះការលំបាកអ្វីខ្លះក្នុងកំឡុងពេលសិក្សា?**



**ចម្លើយ៖** ក្នុងពេលនោះ ខ្ញុំស្ទើរតែមិនមានប្រាក់គ្រប់គ្រាន់ដើម្បីទិញសៀវភៅ និងសម្ភារៈសិក្សាដទៃទៀត ជាពិសេសគឺប្រាក់បង់ថ្លៃសិក្សាភាសាបរទេសដូចជា ភាសាអង់គ្លេស និងបារាំង។ ខ្ញុំមិនមានប្រាក់ទិញអាហារឆ្ងាញ់ៗដូចសិស្សដទៃទៀតទេ។ ជាងនេះទៅទៀត ខ្ញុំត្រូវចំណាយប្រាក់ទិញអាហារ និងជួលផ្ទះ ដែលធ្វើឲ្យខ្ញុំរឹតតែលំបាកថែមទៀតដោយសារតែឪពុកម្ដាយរបស់ខ្ញុំមិនមានលទ្ធភាពផ្គត់ផ្គង់ការចំណាយទាំងនោះ។ ឪពុកម្ដាយរបស់ខ្ញុំបានខាតបង់ក្នុងអាជីព និងជំពាក់ប្រាក់មិត្តភក្តិរបស់គាត់នៅឯទីក្រុងភ្នំពេញ។ ខ្ញុំស្ទើរតែបោះបង់ការសិក្សាទៅធ្វើការដើម្បីទ្រទ្រង់ជីវភាព គ្រួសារ។

**សំណួរ ៣៖ តើលោកដោះស្រាយបញ្ហាទាំងនោះយ៉ាងដូចម្ដេច?**

*តទៅទំព័រ ៦*

## ប្រវត្តិរូបអាជ្ញាកណ្តាល: ពីក្មេង...

*តមកពីទំព័រ ៥*

**ចម្លើយ៖** នៅពេលដែលខ្ញុំទំនេរពីការសិក្សា ខ្ញុំបានធ្វើការងារក្រៅម៉ោងក្នុងកម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ (UNDP) ហើយក្រោយមកនៅទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ប្រាក់បៀវត្សពីការងារ ទាំងនោះល្មមគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ថ្លៃស្នាក់នៅ អាហារ និងប្រាក់បង់សាលា។ ក្រៅពីនេះ ខ្ញុំបានសន្សំប្រាក់កាសខ្លះ សម្រាប់ការសិក្សារបស់ប្អូនស្រីខ្ញុំ។ នៅឆ្នាំដែលខ្ញុំរៀបនឹងបញ្ចប់ការសិក្សា ខ្ញុំមិនអាចធ្វើការច្រើនម៉ោងបានទេ ដោយសារ ខ្ញុំត្រូវយកពេលវេលាសម្រាប់ការសិក្សា។ ខ្ញុំលែងមានប្រាក់ដើម្បីបង់ថ្លៃជួលផ្ទះ តែជាសំណាងល្អ ខ្ញុំបានទទួលការឧបត្ថម្ភពីអង្គការ ដង់ហ្វង់អាស៊ី អាស ប៉េកា (Enfants d'Asie ASPECA)។ អង្គការនេះបានផ្តល់ទីកន្លែងឲ្យខ្ញុំស្នាក់នៅ ហើយខ្ញុំក៏ទទួលបានប្រាក់ឧបត្ថម្ភពីឪពុកធម៌របស់ខ្ញុំនៅប្រទេសបារាំង។ គាត់បានផ្ញើឲ្យខ្ញុំ ៣០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ សម្រាប់ទ្រទ្រង់ការសិក្សារបស់ខ្ញុំ។ បើមិនមានការឧបត្ថម្ភរបស់គាត់ទេនោះ ខ្ញុំគិតថា ខ្ញុំមិនមានប្រាក់ចំណាយសម្រាប់ការ សិក្សាដល់ចប់នោះទេ។

**សំណួរ ៤៖ លោកបានជួបប្រទះឧបសគ្គជាច្រើនក្នុងពេលសិក្សា តើកត្តាអ្វីដែលជម្រុញឲ្យលោកមិនព្រមបោះបង់ និងនៅតែបន្តការសិក្សា?**

**ចម្លើយ៖** ក្តីស្រលាញ់របស់ ឪពុកម្តាយខ្ញុំ។ គាត់ទាំងពីរគឺជាគំរូរបស់ខ្ញុំ។ ពួកគាត់បានបង្រៀនខ្ញុំឲ្យចេះតស៊ូក្នុងជីវិត។ ទោះបីជាពួកគាត់ក្រីក្រ ពួកគាត់តែងតែលើកទឹកចិត្តខ្ញុំឲ្យខិតខំរៀនសូត្រ។ ពួកគាត់មិនបានសន្សំប្រាក់សម្រាប់ជួសជុលផ្ទះទេ ទោះបីជាផ្ទះលិចទឹករាល់ពេលភ្លៀង។ ពួកគាត់ចង់ទុកប្រាក់ទាំងនោះសម្រាប់ការសិក្សារបស់ខ្ញុំ។ ខ្ញុំតែងតែប្រាប់ខ្លួនខ្ញុំ ថាខ្ញុំចង់សង់ផ្ទះថ្មីមួយដល់ឪពុកម្តាយរបស់ខ្ញុំនៅថ្ងៃណាមួយ។ ពេលនេះ ខ្ញុំធ្វើបានហើយ។ ខ្ញុំចង់ប្រាប់ពួកគាត់ថា គាត់មិនចាំបាច់ទ្រាំរស់នៅក្នុងផ្ទះលិចទឹកភ្លៀងទៀតទេ។

**សំណួរ ៥៖ តើលោកទទួលបានជោគជ័យអ្វីខ្លះក្នុងការសិក្សារបស់លោក?**

**ចម្លើយ៖** នៅឆ្នាំ ១៩៩៧ ខ្ញុំទទួលបានរង្វាន់ជាសិស្សពូកែភាសាបារាំង និងគណិតវិទ្យាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្រោយមក ខ្ញុំទទួលបានកម្មវិធីផ្លាស់ប្តូររយៈពេលបីខែទៅសិក្សានៅ ក្រេណូប្លូ (Grenoble) ប្រទេសបារាំង។ នៅឆ្នាំ ២០០០ ខ្ញុំទទួលបានអាហារូបករណ៍ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ទៅបន្តថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកច្បាប់នៅទីក្រុងណាហ្គូយ៉ា ប្រទេសជប៉ុន។

**សំណួរ ៦៖ បច្ចុប្បន្នលោកជាអាជ្ញាកណ្តាលនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល តើលោកមានអារម្មណ៍ដូចម្តេចដែរ?**

**ចម្លើយ៖** កាលពីខ្ញុំនៅក្មេង ខ្ញុំតែងតែប្រាថ្នាចង់ក្លាយជាមេធាវី និងអាជ្ញាកណ្តាល។ ពេលនេះ ក្តីស្រម៉ៃរបស់ខ្ញុំបានក្លាយជាការពិតហើយ ដូច្នេះខ្ញុំមានមោទនភាពក្នុងនាមជាអាជ្ញាកណ្តាល។ ខ្ញុំមិនត្រឹមតែអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមកម្ពុជាប៉ុណ្ណោះទេ ខ្ញុំថែមទាំងអាចជួយប្រជាជនកម្ពុជាផងដែរ។ លើសពីនេះ ខ្ញុំអាចប្រើចំណេះដឹងរបស់ខ្ញុំដើម្បីដោះស្រាយវិវាទការងារជូនកម្មករនិយោជិត និងនិយោជកនៅកម្ពុជា។ ទោះបីជាខ្ញុំមានការរវល់ក្នុងអាជីពជាមេធាវីក្តី ខ្ញុំនៅតែឆ្លៀតពេលអង្គុយជាអាជ្ញាកណ្តាល នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**សំណួរ ៧៖ ក្រោយការបង្កើតរយៈពេល ១០ ឆ្នាំមក ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានទទួលស្គាល់ថាជាស្ថាប័ន ឯករាជ្យ និងយុត្តិធម៌។ តើលោកគិតថាសមាសធាតុទាំងអស់នេះមានសារៈសំខាន់ដូចម្តេចខ្លះ?**

**ចម្លើយ៖** ជាចាំបាច់ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវធានាថាខ្លួនទទួលបានការជឿជាក់ និងទំនុកចិត្តពីអ្នកប្រើប្រាស់សេវារបស់ខ្លួន។ សំខាន់បំផុត អាជ្ញាកណ្តាលទាំងអស់ត្រូវមានវិជ្ជាជីវៈ អព្យាក្រឹតភាព ក្រមសីលធម៌ និងមិនមានភាពលម្អៀងចំពោះភាគីណាមួយ។

**សំណួរ ៨៖ ជាចុងក្រោយក្នុងនាមជាអាជ្ញាកណ្តាលជោគជ័យម្នាក់នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល តើលោកមានដំបូន្មានអ្វីចែករំលែកដល់ក្មេងជំនាន់ក្រោយ ដែលមានបំណងប្រាថ្នាធ្វើជាអាជ្ញាកណ្តាលដូចរូបលោកដែរ?**

**ចម្លើយ៖** ប្អូនៗត្រូវមានជំនាញក្នុងការដោះស្រាយវិវាទការងារព្រោះអាជ្ញាកណ្តាលម្នាក់ៗត្រូវបង្ហាញវិជ្ជាជីវៈ និងចំណាប់អារម្មណ៍កំរិតខ្ពស់ក្នុងការជួយអ្នកដទៃដោយផ្អែកលើការស្វែងរកយុត្តិធម៌ និងការពិត។ អ្វីដែលសំខាន់បំផុតនោះគឺ ប្អូនៗត្រូវខិតខំធ្វើការងារក្នុងជីវិត និងមានគំនិតវិជ្ជមានចំពោះការងាររបស់ខ្លួន។

## សកម្មភាពនៃពេលខាងមុខ: រឿងកំប្លែងបែបអប់រំរបស់មូលនិធិ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបន្តផ្សាយនៅ ស៊ីធីអិន

ជាផ្នែកមួយនៃការបន្តប្រឹងប្រែងលើកកម្ពស់ទៅនឹងដំណើរការដោះស្រាយវិវាទការងារនៅកម្ពុជា មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយមានកិច្ចសហការពីស្ថានីយ៍ទូរទស្សន៍ស៊ីធីអិន ក្នុងកម្មវិធីកំសាន្ត នឹងធ្វើការសំដែងរឿងកំប្លែងបែបអប់រំចំនួន៤រឿង នៅក្នុងកម្មវិធីរាត្រីកំសាន្ត របស់ស្ថានីយ៍ទូរទស្សន៍ស៊ីធីអិន រៀងរាល់ថ្ងៃសៅរ៍ ចាប់ពីខែ សីហា ដល់វិច្ឆិកា ឆ្នាំ២០១៣។

គោលបំណងនៃការសំដែងនេះ គឺដើម្បីប្រាប់ពីការសេវាកម្មដោះស្រាយវិវាទរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដល់កម្មករនិយោជិត និងនិយោជក។ ការប្រើប្រាស់ដំណើរការផ្សះផ្សា និងអាជ្ញាកណ្តាលតាមរយៈស្ថាប័ននេះកម្មករនិយោជិត និងនិយោជក គឺអាចទទួលការដោះស្រាយវិវាទដោយសន្តិវិធី ជៀសវាងការធ្វើកូដកម្ម ឬឡុកអៅ។

កាលពីថ្ងៃទី ១៤ និង ២២ ខែសីហា ឆ្នាំ ២០១៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទើបតែបានបញ្ចប់រឿងកំប្លែងបែបអប់រំចំនួន២ ដែលមានចំណងជើងថា "ដំណើរការដោះស្រាយវិវាទការងារនៅប្រទេសកម្ពុជា" និង "អ្វីជាក្រុមប្រឹក្សាអាជ្ញាកណ្តាល?" ខណៈពេលដែល រឿងកំប្លែងបែបអប់រំចំនួន២ ទៀតដែលនឹងត្រូវបន្តផ្សាយនៅថ្ងៃ ទី១៦ និង ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ កំពុងតែដំណើរ។

## វគ្គជំនាញចរចារបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលឆ្នាំ ២០១៤

ដោយមានបទពិសោធន៍ក្នុងការធ្វើការងារជាមួយនឹងនិយោជកសហជីព និងភាគីពាក់ព័ន្ធដទៃទៀតរយៈពេល ១០ ឆ្នាំក្នុងការងារដោះស្រាយវិវាទការងារ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលស្គាល់ថាការអភិវឌ្ឍជំនាញចរចាមានសារៈសំខាន់ណាស់សម្រាប់បុគ្គលិក និងថ្នាក់គ្រប់គ្រងដើម្បីធានាឲ្យមានទំនាក់ទំនងវិជ្ជាជីវៈក្នុងកន្លែងធ្វើការ។

*តទៅទំព័រ ៧*

## សកម្មភាពនៃពេលខាងមុខ:...

*តមកពីទំព័រ ៦*

នៅដើមឆ្នាំ ២០១៤ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងចាប់ផ្តើមផ្តល់វគ្គបណ្តុះបណ្តាលជំនាញចរចាដល់ថ្នាក់ដឹកនាំ ថ្នាក់គ្រប់គ្រងនិយោជក និងតំណាងនិយោជិតព្រមទាំងជនទាំងឡាយណា ដែលចាប់អារម្មណ៍នឹងការចរចាឲ្យកាន់តែមានប្រសិទ្ធិភាពក្នុងកន្លែងការងាររបស់គាត់ទាំងស្ថាប័នសាធារណៈឯកជន និងអភិវឌ្ឍន៍។

គោលបំណងនៃវគ្គបណ្តុះបណ្តាលគឺដើម្បីពង្រីកចំណេះដឹងរបស់សិក្ខាកាម និងការស្វែងយល់អំពីវិធីសាស្ត្ររួម សម្រាប់ការគ្រប់គ្រងវិបត្តិការដោះស្រាយវិវាទ ។ល។ វគ្គនេះផ្តោតជាសំខាន់លើការជួយភាគីទាំងឡាយឲ្យឈានដល់កិច្ចព្រៀង ដែលផ្តល់លទ្ធភាពឲ្យទទួលបានប្រយោជន៍ទាំងសងខាង និងពង្រឹងទំនាក់ទំនងរវាងភាគីពាក់ព័ន្ធតាមរយៈដំណោះស្រាយដោយសន្តិវិធី និងដោយ មិនចុះញ៉ម។

**ប្រសិនលោកអ្នកត្រូវការព័ត៌មានបន្ថែម សូមទំនាក់ទំនង លោកស្រី សឹង្ហ សុភា មន្ត្រីជាន់ខ្ពស់ផ្នែកសម្របសម្រួល ផ្នែកបណ្តុះបណ្តាលតាមរយៈទូរស័ព្ទលេខ ៖ ០១៧ ៨១៧ ១០៧, ០២៣ ៨៨១ ៨១៤ ខ្សែលេខ ១០៩ ឬអ៊ីម៉ែល:**

**ssoeung@arbitrationcouncil.org**

## បុគ្គលិកថ្មី៖ ប្រធានផ្នែកបណ្តុះបណ្តាល និងទំនាក់ទំនង

នាពេលថ្មីៗនេះ លោក សោ សុន្ទរ៍ផារី បានចូលបម្រើការងារក្នុងគណៈគ្រប់គ្រង ដោយនាំមកជាមួយនូវបទពិសោធន៍គ្រប់គ្រង និងដឹកនាំរយៈពេល ២១ឆ្នាំ ក្នុងអង្គការសហប្រជាជាតិ វិស័យឯកជន និងរាជរដ្ឋាភិបាល។

លោក សោ សុន្ទរ៍ផារី បានចាប់ផ្តើមការងាររបស់គាត់ដំបូងជាមួយនឹងអង្គការសហប្រជាជាតិក្នុងឋានៈជាគ្រូបណ្តុះបណ្តាល និងមន្ត្រីច្បាប់សិទ្ធិមនុស្សរយៈពេល៣ឆ្នាំ មុនពេលលោកប្តូរទៅបម្រើការងារផ្នែកគ្រប់គ្រងអប់រំ-សិក្សាធិការ ក្នុងឋានៈជានាយករងអ្នកគ្រប់គ្រងកម្មវិធី នៃបណ្ឌិតសភាយោធា និងមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការបណ្តុះបណ្តាល និងសាកលវិទ្យាល័យអអឹមអាយធី (RMIT University) ប្រទេសអូស្ត្រាលីរយៈពេល ៨ ឆ្នាំ។ ក្រោយការធ្វើមាតុភូមិនិវត្តពីប្រទេសអូស្ត្រាលី នៅឆ្នាំ ២០០៣ លោក សុន្ទរ៍ផារី បានចូលបម្រើការងារជាប្រធានសម្របសម្រួល នៃគម្រោងដើម្បីអភិវឌ្ឍផ្នែកទំនាក់ទំនងរបស់ប៊ីប៊ីស៊ីវើលសឺវីសត្រាស់ (the BBC World Service Trust's Communications for Development Project) ដែលឧបត្ថម្ភថវិកា ដោយនាយកដ្ឋានអភិវឌ្ឍអន្តរជាតិរបស់ចក្រភពអង់គ្លេសរយៈពេល ៩ឆ្នាំ និងគម្រោងក្រសួងអប់រំយុវជន និងកីឡា និងធនាគារពិភពលោកក្នុងឋានៈជាហិរញ្ញិក និងសមាជិកក្រុមប្រឹក្សាភិបាលរយៈ ៣ឆ្នាំ មុនពេលលោកចូល បម្រើការងារក្នុងក្រុមហ៊ុន ឌីជីថលឌីវ៉ាយដាតា (Digital Divide Data) ក្នុងឋានៈជានាយកគ្រប់គ្រងប្រចាំតំបន់ (ផ្នែកទំនាក់ទំនងខាងក្រៅ និងលក់ផលិតផល)។ គាត់ក៏បានជាប់ឆ្នោត បម្រើការងារជាទីប្រឹក្សាផ្នែកគ្រប់គ្រង និងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ស្ថាប័នជាតិ និងអន្តរជាតិក្នុងវិស័យសេដ្ឋកិច្ច អប់រំ ព័ត៌មានវិទ្យា និងទំនាក់ទំនង (ICT)។



លោក សោ សុន្ទរ៍ផារី កំពុងបន្តការសិក្សាថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ច។ គាត់បានបញ្ចប់អនុបណ្ឌិតគ្រប់គ្រងហិរញ្ញវត្ថុ (សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងលីយ៉ុងដឺ) បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងធុរកិច្ចនៃសាកលវិទ្យាល័យភតឡេនស្តេត (Portland State University) របស់សហរដ្ឋអាមេរិក សញ្ញាប័ត្រគ្រប់គ្រងនៃសាកលវិទ្យាល័យអអឹមអាយធី (RMIT University) ប្រទេសអូស្ត្រាលី បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ចនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង វិញ្ញាបនបត្រច្បាប់នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ គាត់បានទទួលមេដាយមាសចំនួនពីរក្នុងការសិក្សា និងការងារឆ្នើមពីប្រទេសអូស្ត្រាលី និងកម្ពុជា។ គាត់ចូលចិត្តការងារអភិវឌ្ឍសេដ្ឋកិច្ច អប់រំសារព័ត៌មាន និងទំនាក់ទំនងនៅកម្ពុជា និងក្នុងតំបន់។ គាត់បាននិពន្ធសៀវភៅ ដែលមានការបោះពុម្ពផ្សាយនាពេលថ្មីៗនេះដូចជា៖

១. ការបោះឆ្នោតនៅកម្ពុជា (១៩៤៦-២០១៣) ៦៧ឆ្នាំនៃដំណើរនយោបាយសេដ្ឋកិច្ចកម្ពុជា។

២. សេដ្ឋកិច្ចកម្ពុជា-ដំណើរឆ្ពោះទៅកាន់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ និងក្រោយ ២០១៥។

៣. ប្រទេសខ្ញុំជីវិតខ្ញុំ-ដំណើររស់រានឡើងវិញ និងក្តីសង្ឃឹមសម្រាប់អនាគតតាមរយៈការផ្លាស់ប្តូររបបសង្គម។

# ទទួលព័ត៌មានបច្ចុប្បន្នភាពស្ដីពីច្បាប់ការងារ

ចំណេះដឹងផ្នែកការងារ គឺមានភាពចាំបាច់សម្រាប់អ្នកវិជ្ជាជីវៈផ្នែកធនធាន មនុស្ស និយោជក មន្ត្រីសហជីព និងថ្នាក់ ដឹកនាំសហគមន៍ដទៃទៀតដែលធ្វើការដោះស្រាយទៅនឹងបញ្ហាការងារ និងកិច្ចការដែលពាក់ព័ន្ធផ្សេងៗទៀត ។ ច្បាប់ការងារ និងលិខិតបទដ្ឋានការងារផ្សេងៗទៀតក៏មានការវិវត្តន៍ទន្ទឹមទៅនិងការបន្តវិវត្តន៍ទៅមុខរបស់សង្គម និងសេដ្ឋកិច្ចផងដែរ ។ ឧទាហរណ៍ ៖ តើអ្នកមានដឹងពីសេចក្ដីសម្រេចថ្មីៗ ទាក់ទងនឹងកិច្ចសន្យាការងារ ការបង់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ និងការឈប់សម្រាកដោយមានប្រាក់ឈ្នួលទេ? ដូច្នេះហើយ ទោះជាអ្នកជាអ្នកវិជ្ជាជីវៈផ្នែកធនធានមនុស្ស ជាអ្នកតស៊ូមតិផ្នែកការងារជានិស្សិតច្បាប់ ជាសាស្ត្រាចារ្យ ឬក៏ជាអ្នកស្រាវជ្រាវក៏ដោយ វាចាំបាច់ណាស់ថាអ្នកត្រូវទទួលព័ត៌មានបច្ចុប្បន្នភាព ពីការវិវត្តន៍នៅក្នុងច្បាប់ការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានធ្វើការបោះពុម្ពផ្សាយ នូវធនធានឯកសារខាងក្រោមនេះ ដើម្បីជួយអ្នកសម្រេចបានគោលបំណងនេះ៖




- កម្រងសេចក្ដីបង្គាប់ និងសេចក្ដីបញ្ជាអាជ្ញាកណ្ដាលលេខ ១-១៦ (ភាសាអង់គ្លេស)
- កម្រងសេចក្ដីបង្គាប់ និងសេចក្ដីបញ្ជាលេខ ១-២១ (ភាសាខ្មែរ)
- កម្រងច្បាប់ និងលិខិតបទដ្ឋានការងារឆ្នាំ២០១១ (ភាសាខ្មែរ)

**រាល់ឯកសារបោះពុម្ពទាំងអស់នេះ អាចរកជាវបាននៅតាមហាងលក់សៀវភៅនៅភ្នំពេញបានដូចជា បណ្ណាគារ អង្គរធំ បណ្ណាគារ អាស៊ី បណ្ណាគារ អង្គរ និងនៅការិយាល័យក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។**

**សូមទាក់ទងលោកស្រី សឺង្គ សុភា មន្ត្រីជាន់ខ្ពស់សម្របសម្រួលផ្នែកបណ្ដុះបណ្ដាលរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឥឡូវនេះសម្រាប់ការជាវឯកសារបោះពុម្ពទាំងនេះ តាមរយៈអ៊ីម៉ែល៖ ssoeung@arbitrationcouncil.org ឬតាមរយៈលេខទូរស័ព្ទ ០១៧ ៨១៧ ១០៧ (លេខភ្ជាប់បន្ត 109) ។**

**រាល់ការជាវរបស់លោកអ្នក នឹងជួយទ្រទ្រង់ដល់វេទិកាសម្រាប់ការដោះស្រាយវិវាទការងារដោយសន្តិវិធីនៅប្រទេសកម្ពុជា ។**

ផ្លូវលេខ ៧២ ផ្លូវ ៥៩២ ( កែងផ្លូវ ៣២៧ ) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥) ២៣-៨៨១-៨១៤
ទូរសារលេខ: (+៨៥៥) ២៣-៨៨១-៩១៨
អ៊ីម៉ែល: info@arbitrationcouncil.org គេហទំព័រ: www.arbitrationcouncil.org

ប្រសិនបើលោកអ្នកមានចម្ងល់អំពីព្រឹត្តិបត្រក្រុមប្រឹក្សាអាជ្ញាកណ្ដាល សូមទំនាក់ទំនង:
លោក លី សុខហេង / មន្ត្រីទំនាក់ទំនង
ទូរស័ព្ទលេខ: (+៨៥៥) ២៣-៨៨១-៨១៤
ទូរស័ព្ទលេខ : ០១៥ ៩៩៩ ២២៩
អ៊ីម៉ែល : sly@arbitrationcouncil.org